ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

សីហា ២០០៧ / August 2007

ផាន់ ដាលីស / Phann Dalis
ប៉ុន ដូរីណា / Pon Dorina
ហ៊ីង វុទ្ធា / Hing Vutha
ភីម រុនស៊ីណារិទ្ធិ / Phim Runsinarith

បកប្រែដោយៈ យូ សិទ្ធីរិទ្ធ និង យេន សុផានី

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**
*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា
# Main Economic Activities of Cambodia

នៅត្រីមាសទី២ ២០០៧ វិនិយោគឯកជនសរុបមាន ១៩១,៣លានដុល្លារ រឺ ថយចុះ ៦២% ធៀបនឹងត្រីមាសមុន ។ គំរោងអនុមតិក្នុងវិស័យសេវាកម្មបន្តធ្លាក់ចុះអស់ ៥៩% មកត្រឹម ១៣៨,០លានដុល្លារ វិស័យឧស្សាហកម្មធ្លាក់ចុះ ៦៤% មកត្រឹម ៥១,២លានដុល្លារ និងវិស័យកសិកម្ម ធ្លាក់ចុះ ៨៩% មកត្រឹម ២,១លានដុល្លារ ។ ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ គំរោងវិនិយោគឯកជនសរុប ធ្លាក់ចុះ ៩២% ។

Total private investment in the second quarter of 2007 was USD191.3 m, a decrease of 62 percent from the previous quarter. Services sector approvals continued to decline, by 59 percent to USD138.0 m; industry dropped by 64 percent to USD51.2 m, and agriculture declined by 89 percent to USD2.1 m. Compared to the same quarter of 2006, total private investment decreased by 92 percent

**Private Investment Approvals by Sector**
2004 Q4–2007 Q2




*Including expansion projects*
Source: Council for the Development of Cambodia

ចំនួនភ្ញៀវមកដល់កម្ពុជា នៅខែឧសភា ២០០៧ ថយចុះ ២០% ធៀបនឹងខែមុន មកត្រឹម ១៣២.៥១២នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាស ធ្លាក់ចុះ ១១% មកត្រឹម ៨៨.៩៤៥នាក់ រីឯតាមផ្លូវគោក និងផ្លូវទឹក ថយចុះ ៣៣% មកត្រឹម ៤៣.៥៦៧នាក់ ។ ចំនួនភ្ញៀវមកដល់កម្ពុជា ក្នុងបំណងសំរាកលំហែ គឺ ១១១.៦០៧នាក់ រឺ ធ្លាក់ចុះ ១៦% ធៀបនឹងខែមុន ។

Visitor arrivals in Cambodia in May 2007 decreased by 20 percent from the previous month, to 132,512. Arrivals by air dropped by 11 percent to 88,945, and by land and water declined by 33 percent to 43,567. Of the total arrivals in Cambodia, holidayers were 111,607, a fall of 16 percent from the preceding month.

**Cambodia: Foreign Visitor Arrivals**
February 2006–May 2007




Source: Ministry of Tourism

នៅខែឧសភា ២០០៧ អនុមតិគំរោងសាងសង់សរុបនៅភ្នំពេញ កើនដល់ ៧០,៨លានដុល្លារ ធៀបនឹង ១១.៨លានដុល្លារ នៅខែមុន ។ អនុមតិសំណង់ផ្ទះល្វែង កើនពី ៤,៥លានដុល្លារ ដល់ ២២,៥លានដុល្លារ ហើយ សំណង់ភូមិគ្រឹះ និងផ្ទះ កើនពី ០,៩លានដុល្លារ ដល់ ៧,១លានដុល្លារ ។ ធៀបនឹងខែដូចគ្នា ២០០៦ អនុមតិគំរោងសាងសង់សរុប កើន ៧៣% ក្នុងនោះ អនុមតិសំណង់ភូមិគ្រឹះ និងផ្ទះ កើនមួយជាបី ធៀបនឹងមួយឆ្នាំមុន ។

In May 2007, total construction approvals in Phnom Penh increased significantly, from USD11.8 m in the previous month to USD70.8 m. Flat construction approvals rose from USD4.5 m to USD22.5 m, and villa and house approvals rose from USD0.9 m to USD7.1 m. Compared to the same month in 2006, total construction approvals increased by 73 percent, of which villa and house construction approvals increased by three times their value a year earlier.

**Phnom Penh: Value of Construction Approvals**
February 2006–May 2007




Source: Phnom Penh Municipality

# ថ្លៃទំនិញ និង អត្រាការប្រាក់លើប្រាក់បញ្ញើ

# Consumer Prices and Interest Rates on Deposits

នៅខែមិថុនា ២០០៧ ថ្លៃទំនិញទូទៅ កើន ២,០% ធៀបនឹងខែមុន ។ ថ្លៃម្ហូបអាហារកើន ៤,៦% រីឯ ថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ ថយចុះ ០,៩% ។ ធៀបនឹងខែដូចគ្នា ២០០៦ ថ្លៃទំនិញទូទៅកើន ៤,១% ក្នុងនោះ ថ្លៃម្ហូបអាហារកើន ៧,៧% ហើយ ថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ កើន ១,៦% ។

In June 2007, overall prices rose by 2.0 percent from the preceding month. Food prices increased by 4.6 percent, while transportation and telecommunication costs declined by 0.9 percent. As compared with the same month in 2006, overall prices increased by 4.1 percent; food prices rose by 7.7 percent, and transportation and telecommunications by 1.6 percent.

**Phnom Penh: Consumer Price Index**

(July–December 2000=100)

April 2006–June 2007




Source: National Institute of Statistics

នៅខែកក្កដា ២០០៧ សាំងលក់បាន ៣៩៦៩រៀល/លីត្រ រី កើន ០,៧% ធៀបនឹងខែមុន ។ ក្នុងអំឡុងពេលដូចគ្នា ថ្លៃម៉ាស៊ូតកើន ២,១% ដោយលក់បាន ៣១៥៤រៀល/លីត្រ ។ ទោះយ៉ាងនេះក្ដី ចាប់ពីខែដូចគ្នា ២០០៦ ទាំងថ្លៃសាំង និង ម៉ាស៊ូតថយចុះ ៤,១% និង ៤,៧% ។

Gasoline sold at 3969 riels/ℓ in July 2007, an increase of 0.7 percent from the month before. At the same time, diesel rose by 2.1 percent, selling at 3154 riels/ℓ. From the same month in 2006, however, both gasoline and diesel price dropped, by 4.1 percent and 4.7 percent, respectively.

**Phnom Penh: Gasoline & Diesel Prices**

May 2006–July 2007




Sources: CDRI and National Institute of Statistics

អត្រាការប្រាក់លើបញ្ញើធនាគាររយៈ១២ខែ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស (FTB) កាណាឌីយ៉ា និងអេស៊ីលីដា មិនមានការប្រែប្រួលទេ ចាប់ពីឆ្នាំ២០០៥ ។ នៅខែឧសភា ២០០៧ អត្រាការប្រាក់លើបញ្ញើជារៀលរបស់ FTB គឺ ៦,៥% កាណាឌីយ៉ា ៦,០% និងអេស៊ីលីដា ៨,០% ។ រីឯអត្រាការប្រាក់លើបញ្ញើជាដុល្លារវិញ គឺ FTB ៥,០% ហើយ កាណាឌីយ៉ា និងអេស៊ីលីដា ៦,០% ដូចគ្នា។

Interest rates on 12-month bank deposits offered by the Foreign Trade Bank (FTB), Canadia Bank and ACLEDA Bank have been stable since 2005. In May 2007, the riel deposit rate offered by the FTB was 6.5 percent, Canadia Bank 6.0 percent and ACLEDA Bank 8.0 percent. The rate on dollar deposits quoted by the FTB was 5.0 percent, while Canadia Bank and ACLEDA both offered 6.0 percent.

**Interest Rates on 12-Month Bank Deposits**

(As of May 2007)




Source: National Bank of Cambodia

# ស្ថានភាពអត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស

# Exchange Rates and External Development Assistance

នៅខែកក្កដា ២០០៧ ប្រាក់រៀលប្តូរបាន ៤០៨២,៥រៀល/ដុល្លារ រឺកើនឡើង 0,៣% ធៀបនឹងខែមុន ។ ធៀបនឹងខែដូចគ្នា ២០០៦ ប្រាក់រៀល ឡើងថ្លៃ 0,៩% ទល់នឹងប្រាក់ដុល្លារ ។

In July 2007, the riel traded at 4082.5 riels/USD, an appreciation of 0.3 percent from the previous month. Compared to the same month in 2006, the riel appreciated by 0.9 percent against the US dollar.

**Riels per US Dollar**
May 2006–July 2007




Sources: National Bank of Cambodia and CDRI

នៅខែកក្កដា ទល់នឹងប្រាក់បាតថៃ ប្រាក់រៀលប្តូរបាន ១៣២,៦រៀល/បាត ហើយទល់នឹងប្រាក់ដុងវៀតណាម វាប្តូរបាន ២៥,៤រៀល/១០០ដុង ។ ធៀបនឹងខែមុន ប្រាក់រៀលធ្លាក់ថ្លៃ ១២% ទល់នឹងប្រាក់បាត និង ១,៥% ទល់នឹងប្រាក់ដុង ។

The riel traded against the Thai baht at 132.6 riels/baht and against the Vietnamese dong at 25.4 riels per 100 dong in July. The value of the riel depreciated by 12 percent against the baht and 1.5 percent against the dong, compared to the previous month.

**Riels per THB & VND**
May 2006–July 2007




Source: CDRI

ចាប់ពីឆ្នាំ២000 ដល់ ២០០៦ កម្ពុជាបានទទួលការបើកផ្តល់ប្រាក់ចំនួន ៦00លានដុល្លារ សំរាប់ការអភិវឌ្ឍន៍វិស័យសុខាភិបាល ដែលក្តោបលើ សុខភាពផ្លូវចិត្ត ផ្លូវកាយ និងស្មារតីរបស់ប្រជាជន និងសហគមន៍ ។ នៅឆ្នាំ២០០៦ ទឹកប្រាក់ចំនួន ១១0លានដុល្លារ ត្រូវបានបែងចែកសំរាប់វិស័យនេះ ។

From 2000 to 2006, Cambodia received development disbursements amounting to USD600 m for health sector development—covering the mental, physical and spiritual well-being of individuals and their communities. In 2006, USD110 m was allocated to this sector.

**External Development Assistance Disbursement: Health Sector**
2000–2006




Source: CDC, Cambodia Aid Effectiveness Report 2007

# ការអភិវឌ្ឍន៍រូបិយវត្ថុ

# Monetary Developments

នៅខែឧសភា រូបិយវត្ថុទូទៅ (M2) កើនតាមអត្រាប្រចាំឆ្នាំ ៧១% ហើយការផ្គត់ផ្គង់រូបិយវត្ថុ (M1) ធ្លាក់ចុះតាមអត្រាប្រចាំឆ្នាំ ៧,៧% ។ ក្នុងរយៈ ១២ខែ រូបិយវត្ថុទូទៅ (M2) កើន ៤0% ធៀបនឹងកំណើន ៣៥% ក្នុងរយៈមួយឆ្នាំ ដល់ខែមិនា ២00៧ ។

Liquidity (M2) grew at an annualised rate of 71 percent and money supply (M1) fell at an annualised rate of 7.7 percent in May. Over the previous 12 months, M2 grew by 40 percent, compared to a growth of 35 percent in the year to March 2007.

**Monetary Survey**
March 2006–May 2007




Source: National Bank of Cambodia

នៅខែឧសភា ឥណទានក្នុងស្រុកកើនតាមអត្រាប្រចាំឆ្នាំ ៦៩% ហើយឥណទានវិស័យឯកជនកើន តាមអត្រាប្រចាំឆ្នាំ ៦១% ។ ក្នុងរយៈ១២ខែ ដល់ខែឧសភា ឥណទានក្នុងស្រុកកើន ៤២% ធៀបនឹង ៣៦% ក្នុងរយៈមួយឆ្នាំ ដល់ខែមេសា ២00៧ ។

In May, domestic credit increased at an annualised rate of 69 percent and private sector credit grew at an annualised rate of 61 percent. Over the 12 months to May, domestic credit grew by 42 percent, compared to 36 percent in the year to April 2007.

**Domestic Credit**
March 2006–May 2007




Source: National Bank of Cambodia

ឥណទានវិស័យឯកជន នៅខែឧសភា កើន ៤,១% ធៀបនឹងខែមុន ដល់ ៤៣៣៤,៣ពាន់លានរៀល ហើយ ទ្រព្យសកម្មបរទេសសុទ្ធ (NFA) កើន ២,៨% ដល់ ៨៥៧៧,៨ពាន់លានរៀល ។ ឥណទានរដ្ឋាភិបាល ធ្លាក់ចុះ 0,0៥% មកត្រឹម ២៩៧,៧ពាន់លានរៀល រីឯបញ្ញើរដ្ឋាភិបាលកើន ២,៦% ដល់ ១៦៤២,៥ពាន់លានរៀល ។ ក្នុងពេលជាមួយគ្នា បំណុលផ្សេងៗ ដែលមានសញ្ញាអវិជ្ជមាន កើន 0,២% ដល់ ៣២២៥,៥ពាន់លានរៀល ។ បំរែបំរួលនៃប្រតិបត្តិការទាំងនេះ បង្កើនរូបិយវត្ថុទូទៅបាន ៤,៦% ដល់ ៨៣៤១,៩ពាន់លានរៀល ។

Private sector credit in May increased by 4.1 percent from the preceding month to KHR4334.3 bn, and net foreign assets (NFA) rose by 2.8 percent to KHR8577.8 bn. Government credit dropped by 0.05 percent to KHR 297.7 bn, while government deposits rose by 2.6 percent to KHR1642.5 bn. Meanwhile, "other items" which has a negative sign (i.e. is a liability) improved by 0.2 percent to KHR 3225.5 bn. The volatility of these operations increased liquidity by 4.6 percent to KHR8341.9 bn.

**Changes in Monetary Assets**
March 2006–May 2007




Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

ការនាំចេញរបស់កម្ពុជា កើន ៣២% ធៀបនឹងខែមេសា ដល់ ២២០,០លានដុល្លារ នៅខែឧសភា ។ ក្នុងនោះ ការនាំចេញកៅស៊ូ មាន ៣,០លានដុល្លារ កើនមួយជាប្រាំបី ធៀបនឹងខែមុន ការនាំចេញវិស័យកាត់ដេរ កើន ៣០% ដល់ ២១៣,៣លានដុល្លារ រីឯការនាំចេញត្រី ធ្លាក់ចុះ ៥៧% មកត្រឹម ០,១លានដុល្លារ ។ ធៀបនឹងខែដូចគ្នា ឆ្នាំមុន ការនាំចេញសរុបកើន ១១% ក្នុងនោះ ការនាំចេញវិស័យកាត់ដេរ កើន ១២% រីឯការនាំចេញកៅស៊ូ និងត្រីថយចុះ ២៨% និង ៧៨% ។

Cambodia's exports increased by 32 percent from April to USD220.0 m in May. Of total exports, rubber exports were USD3.0 m, an increase of eight times the value in the previous month, garment exports rose by 30 percent to USD213.3 m, while fish exports fell by 57 percent to USD0.1 m. Compared to the same month in the previous year, total exports rose by 11 percent, garment exports increasing by 12 percent while rubber and fish exports declined by 28 percent and 78 percent, respectively.

**Cambodia: Main Exports**
March 2006–May 2007




Source: MEF website

នៅខែឧសភា ២០០៧ ការនាំចូលបារី កើន ៦,៧% ធៀបនឹងខែមុន ដល់ ៤០,៨ពាន់លានរៀល ហើយការនាំចូលស៊ីម៉ង់ត៍ កើន ១៤% ដល់ ១៨,០ លានរៀល ឯការនាំចូលដែក ថយចុះ ១៩% មកត្រឹម ១៤,៣លានរៀល ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ការនាំចូលបារី និងដែក កើន ៣៩% និង ៥៧% រីឯការនាំចូលស៊ីម៉ង់ត៍ ធ្លាក់ចុះ ១១% ។

In May 2007, cigarette imports increased by 6.7 percent from the previous month to KHR40.8 bn, and cement imports rose by 14 percent to KHR18.0 m, while steel imports decreased by 19 percent to KHR14.3 m. Compared to the same month in 2006, cigarette and steel imports rose by 39 percent and 57 percent, respectively, while cement imports dropped by 11 percent.

**Imports: Cigarettes & Construction Material**
March 2006–May 2007




Source: MEF website

នៅខែឧសភា ២០០៧ ការនាំចូលសាំងសរុប មាន ២២.៧៧៦តោន (២៨,៣ពាន់លានរៀល) និងម៉ាស៊ូតមាន ៤៥.៥២៩តោន (៤៦,៧ពាន់លានរៀល) ។ ការនាំចូលសាំង និងម៉ាស៊ូតកើន ១៥% និង ៨,៨% ធៀបនឹងត្រីខែមុន ។

A total of 22,776 tonnes (worth KHR28.3 bn) of gasoline and 45,529 tonnes (KHR46.7 bn) of diesel oil were imported into Cambodia in May 2007. The volume of gasoline and diesel imports increased by 15 percent and 8.8 percent, respectively, from the previous month.

**Imports: Petroleum Products**
March 2006–May 2007




Source: MEF website

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែកុម្ភៈ ២០០៧ ថវិកាចរន្តមានអតិរេក ១១៩,០ពាន់លានរៀល រឺថយចុះ ៤៩% ធៀបនឹងខែមករា ។ ទោះជាដូច្នេះក្តី អតិរេកនេះមានចំនួន៣ដងច្រើនជាងអតិរេកនៅខែដូចគ្នា ឆ្នាំ២០០៦ ។

The current budget surplus was KHR119.0 bn in February 2007; the surplus decreased by 49 percent compared to January. The surplus, however, was three times more than the surplus in the same month in 2006.

**Current Budget Operations**

September 2005–February 2007




*Note: Provisional for2006 and 2007.*
Source: *Monthly Bulletin of Statistics* (MEF website)

នៅខែកុម្ភៈ ២០០៧ ចំណូលចរន្តបានធ្លាក់ចុះ ២,១% ធៀបនឹងខែមុន មកត្រឹម២៥២,៦ពាន់លានរៀល ។ ចំណូលបានមកពីការប្រមូលពន្ធក្នុងស្រុកធ្លាក់ចុះ ១,៤% មកត្រឹម ១៤៨,២ពាន់លានរៀល ហើយចំណូលពន្ធនាំចេញនាំចូល ធ្លាក់ចុះ ៥,៣% មកត្រឹម ៦៨,៤ពាន់លានរៀល ។ ចំណូលមិនមែនពន្ធ កើន ១,៤% ដល់ ៣៦,០ពាន់លានរៀល ។

In February 2007, current revenue collection fell by 2.1 percent from the previous month to KHR252.6 bn. Revenue from domestic tax collections fell by 1.4 percent to KHR148.2 bn and from import and export taxes by 5.3 percent to KHR 68.4 bn. Revenue from non-tax collections increased by 1.4 percent to KHR 36.0 bn.

**Current Budget Revenue**

September 2005–February 2007




*Note: Provisional for 2006 and 2007.*
Source: *Monthly Bulletin of Statistics* (MEF website)

នៅខែកុម្ភៈ ២០០៧ ចំណាយថវិកាចរន្តកើនមួយជាប្រាំ ដល់ ១៣៣,៨ ពាន់លានរៀល ធៀបនឹងខែមករា ។ ចំណាយលើប្រាក់បៀវត្សរ៍ កើនមួយជាប្រាំ ដល់ ៧១,៦ពាន់លានរៀល រីឯ ឧបត្ថម្ភធននិងជំនួយសង្គមកិច្ច ក៏កើនមួយជាប្រាំដែរ ដល់ ២០,៧ពាន់លានរៀល រីឯចំណាយលើសេវាកម្មផ្សេងៗ មានចំនួន ៤១,៤ពាន់លានរៀល។ ចំណាយរបស់រដ្ឋាភិបាល នៅខែកុម្ភៈ ២០០៧ មានក៏រិត ១១% តិចជាងចំណាយនៅខែដូចគ្នា ឆ្នាំ២០០៦ ។

Current budget expenditure increased by five times the value in January to KHR133.8 bn in February 2007. Spending on wages increased by five times to KHR71.6 bn; subsidy and social assistance rose by five times to KHR20.7 bn, and other services were KHR41.4 bn. Government spending in February 2007, however, was 11 percent less than spending in the same month of 2006.

**Current Budget Expenditure Components**

December 2005–February 2007




*Note: Provisional for 2006 and 2007.*
Source: *Monthly Bulletin of Statistics* (MEF website)

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែឧសភា ការនាំចេញទំនិញរបស់ US និងតំបន់អឺរ៉ូ កើនឡើង ។ ការនាំចេញទំនិញរបស់US កើន ២,៤% ធៀបនឹងខែមុន ដល់៩៣,៣០ពាន់លានដុល្លារ រីឯការនាំចេញទំនិញរបស់តំបន់អឺរ៉ូ កើន ០,៧% ដល់ ១៦៧,៨៤ពាន់លានដុល្លារ ។ ចំពោះការនាំចេញទំនិញរបស់ជប៉ុនសំរាប់ខែឧសភា គឺមិនទាន់មានទិន្នន័យនៅឡើយទេ ។

In May, goods exports of the US and the Euro zone increased. US goods exports rose by 2.4 percent from the previous month to USD93.30 bn, while goods exports of the Euro zone increased by 0.7 percent to USD167.84 bn. Japan's export data for May have not yet been made available.

**Goods Exports: US, Euro Zone & Japan**
May 2006–May 2007




Sources: BEA, Eurostat and JETRO

នៅខែឧសភា ចិនមានអតិរេកពាណិជ្ជកម្ម ២២,៤៨ពាន់លានដុល្លារ ធៀបនឹង ១៦,៨៥ពាន់លានដុល្លារ នៅខែមេសា ។ ការនាំចេញសរុបថយចុះ ៣,៥% ធៀបនឹងខែមុន មកត្រឹម ៩៤,០៧ពាន់លានដុល្លារ រីឯការនាំចូលសរុបធ្លាក់ចុះ ១១% មកត្រឹម ៧១,៥៩ពាន់លានដុល្លារ ។

In May, China recorded a trade surplus of USD22.48 bn, compared to USD16.85 bn in April. Total exports decreased by 3.5 percent from the previous month to USD94.07 bn, while total imports fell by 11 percent to USD71.59 bn.

**External Trade: China**
May 2006–May 2007




Sources: National Bureau of Statistics of China

នៅខែឧសភា ម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្ម ២,៣២ពាន់លានដុល្លារ ធៀបនឹង ១,៧៣ពាន់លានដុល្លារ នៅខែមេសា ។ ទាំងការនាំចេញ និងការនាំចូល កើនយ៉ាងខ្លាំងធៀបនឹងខែមុន ។ ការនាំចេញ នៅខែឧសភាមាន ១៤,៥៨ពាន់លានដុល្លារ ដោយកើនពី ១៣,៣០ពាន់លានដុល្លារ នៅខែមេសា រីឯការនាំចូលមាន ១២,២៦ពាន់លានដុល្លារ ធៀបនឹង ១១,៥៧ពាន់លានដុល្លារ នៅខែមេសា ។

In May, Malaysia recorded a trade surplus of USD2.32 bn, compared to USD1.73 bn in April. Both exports and imports increased considerably from the previous month. Exports in May were USD14.58 bn, up from USD13.30 bn. in April. Imports were USD12.26 bn., compared to USD11.57 bn. in April.

**External Trade: Malaysia**
May 2006–May 2007




Source: Department of Statistics, Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា
# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់របស់US កើន ២,៧% នៅរយៈមួយឆ្នាំដល់ខែឧសភា ។ យោងតាមក្រសួងការងាររបស់ US កំណើននេះបណ្តាលមកពីកំណើនថ្លៃម្ហូបអាហារ ការស្នាក់នៅ ការថែទាំសុខភាព ការអប់រំ និងទូរគមនាគមន៍ ។ ក្នុងអំឡុងពេលដូចគ្នា អតិផរណា មានអត្រា ១,៩% នៅតំបន់អឺរ៉ូ និងមានអត្រាសូន្យនៅជប៉ុន ។

US consumer prices increased by 2.7 percent in the year to May. According to the US Department of Labour, this largely reflected higher charges for food, housing, medical care, education and communication. During the same period, the inflation rate was 1.9 percent in the Euro zone and nil in Japan.

**Inflation Rate: US, Euro Zone & Japan**

(change from a year earlier)




*Note: The latest data available are for May 2007.*
Sources: IMF and *Economist* (26 July 2007)

ក្នុងរយៈមួយឆ្នាំដល់ខែឧសភា ថ្លៃទំនិញប្រើប្រាស់នៅហុងកុង កើន ១,២% គឺ ទាបជាងកំណើន ២,៤% នៅខែមុន ។ ក្នុងអំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់នៅចិន និងកូរ៉េខាងត្បូងកើន ៣,៤% និង ២,៣% ។

Hong Kong's consumer prices rose by 1.2 percent in the year to May, less than the 2.4 percent increase a month earlier. During the same period, consumer prices in both China and South Korea increased, by 3.4 percent and 2.3 percent, respectively.

**Inflation Rate: China, Hong Kong & South Korea**

(change from a year earlier)




*Note: The latest data available are for May 2007.*
Sources: IMF and *Economist* (26 July 2007)

នៅខែឧសភា ២០០៧ ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី កើន ១% ធៀបនឹងខែដូចគ្នា មួយឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី កំណើននេះ បណ្តាលមកពីការឡើងថ្លៃម្ហូបអាហារ ថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ ការថែទាំសុខភាព និងការលំហែកំសាន្ត ។ ក្នុងអំឡុងពេលដូចគ្នា អត្រាអតិផរណាក្នុងរយៈមួយឆ្នាំ មានកំរិត ១,៤% នៅម៉ាឡេស៊ី និង ១,៩% នៅថៃ ។

Singapore's consumer price index in May 2007 was one percent higher than in the same month a year earlier. The Department of Statistics of Singapore attributed this to higher costs for food, transport and communication, health care and recreation. During the same period, the year-on-year inflation rate was 1.4 percent in Malaysia and 1.9 percent in Thailand.

**Inflation Rate: Selected ASEAN Countries**

(change from a year ago)




*Note: The latest data available are for May 2007*
Sources: IMF and *Economist* (26 July 2007)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rates in World Markets

នៅខែកក្កដា ២០០៧ ដុល្លារUS ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុធំបងៗភាគច្រើន ។ ទល់នឹងប្រាក់អឺរ៉ូ វាប្តូរបាន ០,៧៣អឺរ៉ូ/ដុល្លារ រឺ ធ្លាក់ថ្លៃ ២,២% ធៀបនឹងខែមុន ។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្តូរបាន ១២១,៥យ៉េន/ដុល្លារ រឺ ធ្លាក់ថ្លៃ ១% ធៀបនឹងខែមុន ។

In July 2007, the US dollar lost value against most major currencies. Against the euro, it traded at 0.73 EUR/USD, a 2.2 percent fall from a month earlier. Against the Japanese yen, it exchanged at 121.5 JPY/USD, a one percent depreciation compared to the preceding month.

**EUR & JPY per USD**

July 06–July 07 (monthly average)




Source: Federal Reserve Bank of New York

នៅខែកក្កដា ២០០៧ ប្រាក់វ៉ុនកូរ៉េខាងត្បូងប្តូរបាន ៩១៨,១០វ៉ុន/ដុល្លារ រឺ ធ្លាក់ថ្លៃ ១,១% ធៀបនឹងខែមិថុនា ២០០៧ ។ ក្នុងអំឡុងពេលដូចគ្នា ដុល្លារហុងកុងរក្សាថ្លៃនៅដដែល ដោយប្តូរបាន ៧,៨២ដុល្លារហុងកុង/ដុល្លារUS ។

In July 2007, the South Korean won exchanged at 918.10 per US dollar, a 1.1 depreciation from June. During the same month, the Hong Kong dollar remained steady, trading at 7.82 HKD/USD.

**KRW & HKD per USD**

July 06–July 07 (monthly average)




Source: Federal Reserve Bank of New York

នៅខែកក្កដា ដុល្លារសិង្ហបុរីឡើងថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ១,៥១៦ដុល្លារសិង្ហបុរី/ដុល្លារUS ធៀបនឹង ១,៥៣៧ដុល្លារសិង្ហបុរី/ដុល្លារUS នៅខែមុន ។ ប្រាក់បាតថៃឡើងថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ៣០,៤៥បាត/ដុល្លារUS រឺ ឡើងថ្លៃ ៥,៨% ធៀបនឹងខែមិថុនា ឆ្នាំ២០០៧ ។

In July, the Singapore dollar rate advanced against the US dollar, trading at 1.516 SGD/USD compared to 1.537 a month earlier. The Thai baht appreciated against the US dollar, exchanging at 30.45 per dollar, a 5.8 percent improvement from June 2007.

**THB & SGD per USD**

July 06–July 07 (monthly average)




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែមិថុនា ថ្លៃអង្ករពិភពលោកកើនឡើងដោយសារមានតំរូវការនាំចូលខ្លាំង និងការផ្គត់ផ្គង់សំរាប់នាំចេញមានតិច ។ សន្ទស្សន៍ថ្លៃទំនិញអន្តរជាតិ (IPO) មាន ១៣៩,៦ពិន្ទុ គឺខ្ពស់ជាង ១៣៧,៦ពិន្ទុ នៅខែឧសភា។ នៅថៃ ថ្លៃអង្ករ Thai100%B កើន ៣,១% ធៀបនឹងខែមុន ដល់ ៣០៤,៧៥ ដុល្លារUS/តោន ។ នៅ US ថ្លៃអង្ករនាំចេញ ធ្លាក់ចុះ ១,០% ធៀបនឹងខែមុន មកត្រឹម ៣៧២,៧៧ដុល្លារ/តោន ។

In June, world rice prices increased due to a strong import demand and limited exportable supply. The International Prices Index (IPO) was 139.6, up from 137.6 in May. In Thailand, the price of Thai 100% B rose by 3.1 percent from the previous month to USD304.75 per tonne. In the United States, the export price decreased by 1.0 percent from the previous month to USD372.77 per tonne.

**Rice: International Prices Index & Export Prices**
June 2006–June 2007




Sources: Osiriz/InfoArroz and InterRice.

នៅខែកក្កដា សណ្តែកសៀងឡើងថ្លៃ រីឯពោតធ្លាក់ថ្លៃ ។ សណ្តែកសៀងលក់ថ្លៃ ២៨៧,១៨ដុល្លារ/តោន គឺខ្ពស់ជាង ២៧៧,៣៨ដុល្លារ/តោន នៅខែមិថុនា ។ ពោតលក់ថ្លៃ ១៥៤,៣០ដុល្លារ/តោន រឺ ធ្លាក់ថ្លៃ ១០% ធៀបនឹងខែមុន ។ នៅខែមិថុនា ប្រេងឆាឡើងថ្លៃ ៤,៣% ធៀបនឹងខែមុន ដល់ ៧៣០,១៤ដុល្លារ/តោន ។

In July, the price of soybeans increased, while the price of maize decreased. Soybeans sold at USD287.18 per tonne, up from USD277.38 in June. Maize was USD154.30 per tonne, a 10 percent decline from the previous month. In June, the price of palm oil increased by 4.3 percent from the previous month to USD730.14 per tonne.

**Prices: Soybeans, Maize & Palm Oil**
July 2006–July 2007




Source: Food and Agriculture Organisation (FAO)

នៅខែកក្កដា ប្រេងឆៅ សាំង និងម៉ាស៊ូត ឡើងថ្លៃ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៧១,៩៤ដុល្លារ/ធុង ធៀបនឹង ៦៧,០០ ដុល្លារ/ធុង នៅខែមិថុនា ។ នៅ US Gulf Coast សាំងធម្មតា (អុកតាន ៨៧) ឡើងថ្លៃ ៣,២% ធៀបនឹងខែមុន ដល់ ៥៩,០៩សេន/លីត្រ ។ រីឯម៉ាស៊ូត (មានលាយស្ពាន់ធ័រតិច លេខ២) ឡើងថ្លៃ ៣,៥% ធៀបនឹងខែមុន ដល់ ៥៦,៥៨សេន/លីត្រ ។

In July the prices of crude oil, gasoline and diesel increased. The OPEC crude oil spot price was USD71.94 per barrel, against USD67.00 in June. Regular gasoline (87 octane) on the US Gulf Coast rose by 3.2 percent from the previous month to 59.09 cents per litre. Diesel (low sulphur No.2) on the US Gulf Coast rose by 3.5 percent from the previous month, to 56.58 cents per litre.

**Prices: Crude Oil, Gasoline & Diesel**
July 2006–July 2007




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

**ក្រុមហ៊ុនជប៉ុន នឹងវិនិយោគលើជីវម៉ាស៊ូតនៅកម្ពុជា:** ក្រុមហ៊ុនជប៉ុនមួយនឹងវិនិយោគ ៨០០លានដុល្លារ នៅកម្ពុជា សំរាប់ដាំល្ហុងខ្វៃ និងចំរាញ់ប្រេងរបស់វាទៅជាជីវម៉ាស៊ូត ។ លោក Mitsuo Hayashi ប្រធានផ្នែកប្រតិបត្តិក្រុមហ៊ុនជីវពិសោធន៏ Biwako ខូអិលធីឌី មានប្រសាសន៏ថា ក្រុមហ៊ុននឹងដាំល្ហុងខ្វៃលើផ្ទៃដី ៤៨.០០០ហិកតា នៅខេត្តកំពង់ស្ពឺ និងកំពង់ចាម និងបន្ទាប់មកបង្កើតរោងចក្រសំរាប់ចំរាញ់ប្រេងល្ហុងខ្វៃឱ្យទៅជាជីវម៉ាស៊ូត ដើម្បីជំនួសឱ្យសាំង ។ គាត់ បានបន្តថា ដើមល្ហុងខ្វៃលើផ្ទៃដី ៤៨.០០០ហិកតា នឹងផ្តល់ប្រេង ១០០.០០០តោន ជារៀងរាល់ឆ្នាំ ដែលអាចចំរាញ់ជីវម៉ាស៊ូតបាន ៤០.០០០តោន ។ ក្រុមហ៊ុនត្រូវការដី ៥០០.០០០ហិកតា សំរាប់គំរោងរយៈពេល២០ឆ្នាំ ហើយបច្ចុប្បន្ន រដ្ឋាភិបាលកំពុងជួយស្វែងរកដីសំរាប់គំរោងនេះ ។

***Japanese company to invest in Cambodia for bio-diesel:*** A Japanese company will invest USD800 m in Cambodia to plant castor beans and refine castor oil into bio-diesel. The Biwako Bio-Laboratory Co. Ltd. will plant castor beans on 48,000 hectares in Kompong Speu and Kompong Cham provinces and then establish a factory to refine castor oil into bio-diesel which is expected to replace gasoline, said Mitsuo Hayashi, chief executive officer of the company. Some 48,000 hectares of castor plants will yield 100,000 tons of castor oil annually and 40,000 tons of bio-diesel after refining, he said. The company needs 500,000 hectares of land for the project over 20 years, and the Cambodian government is now helping to find the land. *(Cited from Xinhua, 20 July 2007)*

**ក្រុមហ៊ុនUS នឹងវិនិយោគ ១០០លានដុល្លារលើផ្នែកព័ត៌មានវិទ្យា (IT):** លោក Patrick J. McGovern នាយកក្រុមហ៊ុន IDG (ក្រុមប្រមូលទិន្នន័យអន្តរជាតិ) របស់ US បានជំរាបដល់ឧបនាយករដ្ឋមន្ត្រី សុខ អាន ក្នុងកិច្ចប្រជុំកាលពីថ្ងៃ៩ កក្កដា នៅទីស្តីការគណៈរដ្ឋមន្ត្រីថា IDG គ្រោងនឹងវិនិយោគ ១០០លានដុល្លារ សំរាប់វិស័យព័ត៌មានវិទ្យានៅកម្ពុជា ។

***US firm to invest USD100 m in IT:*** The US International Data Group (IDG) plans to invest some USD100 m in Cambodia's information technology sector, IDG director Patrick J. McGovern told Deputy Prime Minister Sok An during a meeting on 9 July at the Council of Ministers. *(Cited from Kampuchea Thmey, 11 July 2007)*

**ជប៉ុន នឹងផ្តល់កំចីដល់កម្ពុជាសំរាប់កម្មវិធីវិនិយោគវិស័យឯកជន:** ធនាគារជប៉ុនសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ នឹងផ្តល់កំចីការប្រាក់ទាបចំនួន ៨លានដុល្លារ ដល់កម្ពុជា ដើម្បីជំរុញដល់កម្មវិធីវិនិយោគវិស័យឯកជន ។ កម្មវិធីមានគោលដៅទាក់ទាញវិនិយោគិនជប៉ុនថ្មីៗមកកម្ពុជា និងការពារពួកអ្នកដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគនៅកម្ពុជា។

***Japan to grant loan to Cambodia for private investment programmes:*** The Japan Bank for International Cooperation will grant Cambodia a USD8 m soft loan to boost private sector investment programmes. These programmes aim to attract new Japanese investors to Cambodia and protect those who have recently signed investment deals in the country. *(Cited from Xinhua,24 July 2007)*

**កូរ៉េខាងត្បូង នឹងផ្តល់ប្រាក់កំចី ៣០លានដុល្លារដល់កម្ពុជាសំរាប់បំពាក់ប្រព័ន្ធព័ត៌មានវិទ្យារបស់រដ្ឋាភិបាល:** ក្រុមហ៊ុន Kisan Telecom ខូអិលធីឌី របស់កូរ៉េខាងត្បូង បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយជាមួយរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់ប្រាក់កំចី ៣០លានដុល្លារលើគំរោងប្រព័ន្ធព័ត៌មានវិទ្យា សំរាប់វិស័យសាធារណៈនៅកម្ពុជា ។ កំចី នឹងត្រូវចំណាយលើការបំពាក់ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យារបស់រដ្ឋាភិបាល រួមទាំង ប្រព័ន្ធអ៊ិនធឺណិតសំរាប់ស្ថាប័នរដ្ឋាភិបាល នៅ ១០ ខេត្តក្រុង ។

***South Korea provides USD30 m loan to Cambodia to equip government's IT system:*** The South Korean company Kisan Telecom Co. Ltd. has signed an agreement with the Cambodian government to provide a loan of USD30 m for a public information technology project in Cambodia. The loan will be used to equip the government's IT management system, including internet access for government institutions in 10 provinces and cities. *(Cited from Xinhua, 20 July 2007)*

**វៀតណាម នឹងតភ្ជាប់ផ្លូវរថភ្លើងជាមួយកម្ពុជា និងឡាវ:** វៀតណាមគ្រោងសាងសង់ផ្លូវរថភ្លើង២ខ្សែតភ្ជាប់មកកម្ពុជា និងឡាវ ដែលជាផ្នែកមួយនៃផ្លូវរថភ្លើង Trans-Asia ដើម្បីជួយសំរួលដល់អ្នកដំណើរ និងការដឹកជញ្ជូនទំនិញ។ ផ្លូវរថភ្លើង Trans-Asia មានប្រវែង ៥៥០០គីឡូម៉ែត្រ និងផ្តើមចេញពី គូនមីង ខេត្តយូណាន ប្រទេសចិន រួចឆ្លងកាត់តាមឡាវ ភូមា ថៃ វៀតណាម កម្ពុជា និង ម៉ាឡេស៊ី ហើយទៅបញ្ចប់ នៅសិង្ហបុរី ។ ផ្លូវរថភ្លើង Trans-Asia ចាប់ផ្តើមសាងសង់នៅម៉ាឡេស៊ី ក្នុងឆ្នាំ១៩៩៥ ហើយសង្ឃឹមថានឹងបញ្ចប់ នៅឆ្នាំ២០១៥ ។

***Vietnam to link railways with Cambodia, Laos:*** Vietnam is planning to build two rail routes running to Cambodia and Laos, part of the Trans-Asia Railway, to facilitate passenger and cargo transport in the region. The two future routes are part of the 5500-km railway, which is to begin in Kunming, China's Yunnan province, and travel through Laos, Myanmar, Thailand, Vietnam, Cambodia and Malaysia before terminating in Singapore. The Trans-Asia Railway, initiated by Malaysia in 1995, is expected to be completed in 2015. *(Cited from Xinhua, 1 July 2007)*